# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤០៥ ប្រក. កសក

## ប្រកាស

## ស្តីពី

## បែបបទ និងនីតិវិធីនៃការផ្តល់លិខិតទទួលស្គាល់ជាផ្ទុកការ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា

---

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ. បក ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ. បក ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- បានឃើញប្រកាសលេខ ០៨៦ ប្រក.កសក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០០៤ ស្តីពីការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- តាមសំណើរបស់នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ៗ

# សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់នូវបែបបទ និងនីតិវិធីនៃការផ្តល់លិខិតទទួលស្គាល់ជាផ្លូវការ និងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ក្នុងគោលបំណងធានានូវគុណភាពជាក់លាក់នៃកៅស៊ូកម្ពុជា តាមរយៈការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ និងមន្ទីរពិសោធន៍មូលដ្ឋាន ព្រមទាំងការផ្តល់លិខិតទទួលស្គាល់ជាផ្លូវការ និងលិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា សំដៅធានាបាននូវជំនឿទុកចិត្តចំពោះទីផ្សារជាតិ និងអន្តរជាតិក្នុងការធ្វើពាណិជ្ជកម្មកៅស៊ូដែលមានប្រភពដើមផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អ្នកកែច្នៃកៅស៊ូដែលមានបំណងផលិត និងស្នើសុំវិញ្ញាបនបត្រយថាប្រភេទកៅស៊ូកម្ពុជា ត្រូវស្នើសុំចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូរបស់ខ្លួននៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា។ សំណុំបែបបទពាក់ព័ន្ធនឹងការចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ទី២ និង ទី៣ ភ្ជាប់ប្រកាសនេះ ។

ក្រោយពេលទទួលពាក្យស្នើសុំ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវចាត់មន្ត្រីចុះធ្វើការត្រួតពិនិត្យ និងវាយតម្លៃនៅរោងចក្រដោយផ្ទាល់។ នីតិវិធីនៃការត្រួតពិនិត្យនិងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ៤ ភ្ជាប់ប្រកាសនេះ។

**ប្រការ ៣ :** ក្នុងករណីរោងចក្រកែច្នៃកៅស៊ូបំពេញបានភាពអនុលោមស្របតាមលក្ខខណ្ឌបច្ចេកទេសវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវចុះបញ្ជិការោងចក្រនោះ និង ផ្តល់លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា។ ម្ចាស់រោងចក្រកែច្នៃកៅស៊ូសាមីមានកាតព្វកិច្ចបង់កម្រៃសេវាកម្មសម្រាប់ចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ និង កម្រៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ជូនវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**ប្រការ ៤ :** រាល់មន្ទីរពិសោធន៍មូលដ្ឋាន ដែលមានបំណងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ត្រូវស្នើសុំចុះបញ្ជិកាមន្ទីរពិសោធន៍របស់ខ្លួន ស្នើសុំលិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានសិទ្ធិចេញវិញ្ញាបនបត្រ និង សិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ។ សំណុំបែបបទពាក់ព័ន្ធការចុះបញ្ជិកាមន្ទីរពិសោធន៍យថាប្រភេទត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ៥ ភ្ជាប់ប្រកាសនេះ ។

ក្រោយពេលទទួលពាក្យស្នើសុំ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាត្រូវចាត់មន្ត្រីដើម្បីចុះធ្វើការត្រួតពិនិត្យ និងវាយតម្លៃនៅមន្ទីរពិសោធន៍មូលដ្ឋាននោះដោយផ្ទាល់។ នីតិវិធីនៃការត្រួតពិនិត្យ និងវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋានត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ភ្ជាប់ប្រកាសនេះ ។

**ប្រការ ៥ :** ក្នុងករណីមន្ទីរពិសោធន៍មូលដ្ឋានបំពេញបានភាពអនុលោមស្របតាមលក្ខខណ្ឌបច្ចេកទេស វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវចុះបញ្ជិកាមន្ទីរពិសោធន៍នោះ និងអនុញ្ញាតឱ្យមន្ទីរពិសោធន៍នោះចូលរួមធ្វើតេស្តប្រៀបធៀប ឬ តេស្តផ្សេងៗទៀត តាមការកំណត់របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានលិខិតទទួលស្គាល់ជាផ្លូវការ។ វិធីសាស្ត្រធ្វើតេស្តប្រៀបធៀបត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ៧ ភ្ជាប់ប្រកាសនេះ ។

ម្ចាស់មន្ទីរពិសោធន៍មូលដ្ឋានមានកាតព្វកិច្ចបង់កម្រៃសេវាកម្មសម្រាប់ការចុះបញ្ជិកាមន្ទីរពិសោធន៍របស់ខ្លួន កម្រៃទទួលស្គាល់ជាផ្លូវការ និង កម្រៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ជូនវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**ប្រការ ៦ :** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមានសិទ្ធិព្យួរបញ្ជិការោងចក្រកែច្នៃកៅស៊ូ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ក្នុងរយៈពេលមិនលើសពី ០៦ (ប្រាំមួយ)ខែ ក្នុងករណីពិនិត្យឃើញថា ម្ចាស់រោងចក្រកែច្នៃកៅស៊ូនោះបានប្រព្រឹត្តកំហុសណាមួយដូចខាងក្រោម ÷

១-អនុវត្តពុំសមស្របតាមលក្ខខណ្ឌនៃការចុះបញ្ជិកា ឬ លក្ខខណ្ឌបច្ចេកទេស ។

២-ប្រើប្រាស់វិញ្ញាបនបត្រ ឬ ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាមិនត្រឹមត្រូវ ។

បញ្ជិការោងចក្រកែច្នៃកៅស៊ូត្រូវបានលុបចោល ហើយលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាត្រូវបានដកហូតដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្នុងករណីម្ចាស់រោងចក្រកែច្នៃកៅស៊ូបានប្រព្រឹត្តកំហុសណាមួយដូចខាងក្រោម ÷

១-មិនបានបំពេញលក្ខខណ្ឌទាំងឡាយដែលបានតម្រូវឱ្យធ្វើការកែតម្រូវក្នុងរយៈពេលព្យួរ ។

២-បានប្រព្រឹត្តកំហុសដដែលៗដូចគ្នាទៅនឹងកំហុសដែលបានបណ្តាលឱ្យមានការព្យួរលើកមុន ។

៣-អនុវត្តខុសពីបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

**ប្រការ ៧ :** ដំណើរការនៃការព្យួរ ឬ លុបចោលបញ្ជិការោងចក្រកែច្នៃកៅស៊ូ ឬ ដកហូតលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវអនុវត្តតាមវិធានដូចខាងក្រោម ÷

១-វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលសម្រេចលើការព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវផ្ញើលិខិតជូនដំណឹងទៅឱ្យរោងចក្រ

កែច្នៃកៅស៊ូ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុន និងបញ្ជាក់អំពីមូលហេតុដែលនាំឱ្យមានការព្យួរ ឬ លុបចោល ឬ ដកហូត ហើយតម្រូវឱ្យអនុវត្តវិធានការកែតម្រូវ ។

២-វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបញ្ជូនលិខិតចម្លង ស្តីពីការសម្រេចព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជានេះ ជូនទៅស្ថាប័នអាណាព្យាបាល ឬ ភ្នាក់ងារពាក់ព័ន្ធអំពីវិញ្ញាបនកម្មយថាប្រភេទកៅស៊ូកម្ពុជា ដើម្បីបញ្ជាក់ថាបញ្ជិកា និងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវបានព្យួរ ឬ លុបចោល ឬ ដកហូត។ រោងចក្រកែច្នៃកៅស៊ូដែលត្រូវបានព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា មិនមានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងទទួលបានវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ក្នុងដំណាក់កាលព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

៣-បន្ទាប់ពីបានអនុវត្តវិធានការកែតម្រូវរួចហើយ រោងចក្រកែច្នៃកៅស៊ូដែលត្រូវបានព្យួរ ត្រូវធ្វើលិខិតជូនដំណឹងមកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីអនុវត្តនីតិវិធីត្រួតពិនិត្យ និងវាយតម្លៃឡើងវិញ។ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អាចលុបចោលការព្យួរក្នុងករណីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃមានលក្ខណៈវិជ្ជមាន។

**ប្រការ ៨ :** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមានសិទ្ធិព្យួរបញ្ជិកា លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងលិខិតទទួលស្គាល់ជាផ្លូវការរបស់មន្ទីរពិសោធន៍មូលដ្ឋានក្នុងរយៈពេលមិនលើសពី ០៦ (ប្រាំមួយ) ខែ ក្នុងករណីពិនិត្យឃើញថាម្ចាស់មន្ទីរពិសោធន៍នោះបានប្រព្រឹត្តកំហុសណាមួយដូចខាងក្រោម÷

១- អនុវត្តពុំសមស្របតាមលក្ខខណ្ឌនៃការចុះបញ្ជិកា លិខិតទទួលស្គាល់ជាផ្លូវការ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ឬ លក្ខខណ្ឌបច្ចេកទេស កំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

២- មិនទទួលបានលទ្ធផលវិជ្ជមានក្នុងការធ្វើតេស្តប្រៀបធៀប ។

៣- ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ឬ ប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាមិនត្រឹមត្រូវ។

បញ្ជិកាត្រូវបានលុបចោល និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងលិខិតទទួលស្គាល់ជាផ្លូវការ ត្រូវបានដកហូតដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្នុងករណីម្ចាស់មន្ទីរពិសោធន៍បានប្រព្រឹត្តកំហុសណាមួយដូចខាងក្រោម÷

១- មិនបានបំពេញលក្ខខណ្ឌទាំងឡាយដែលបានតម្រូវឱ្យធ្វើការកែតម្រូវក្នុងរយៈពេលព្យួរ ។

២- បានប្រព្រឹត្តកំហុសដដែល១ ដូចគ្នាទៅនឹងកំហុសដែលបណ្តាលឱ្យមានការព្យួរលើកមុន ។

៣- បានឃុបឃិតក្លែងបន្លំគុណភាពយថាប្រភេទកៅស៊ូខុសពីគុណភាពជាក់ស្តែង ។ ⁄

**ប្រការ ៩ :** ដំណើរការនៃការព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការមន្ទីរពិសោធន៍មូលដ្ឋាន និងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវអនុវត្តតាមវិធានដូចខាងក្រោម ÷

១-វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលសម្រេចលើការព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវផ្ញើលិខិតជូនដំណឹងទៅឱ្យមន្ទីរពិសោធន៍មូលដ្ឋាន ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុន និងបញ្ជាក់អំពីមូលហេតុដែលនាំឱ្យមានការព្យួរ ឬ លុបចោល ឬ ដកហូត ហើយតម្រូវឱ្យអនុវត្ត វិធានការកែតម្រូវ ។

២-វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបញ្ជូនលិខិតចម្លង ស្តីពីការសម្រេចព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ និងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ជូនទៅស្ថាប័នអាណាព្យាបាល ឬ ភ្នាក់ងារពាក់ព័ន្ធអំពីវិញ្ញាបនកម្មយថាប្រភេទកៅស៊ូកម្ពុជា ដើម្បីបញ្ជាក់ថា បញ្ជិកា លិខិតទទួលស្គាល់ជាផ្លូវការ និងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវបានព្យួរ ឬ លុបចោល ឬ ដកហូត។

មន្ទីរពិសោធន៍មូលដ្ឋានដែលត្រូវបានព្យួរ ឬ លុបចោលបញ្ជិកា ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ និងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា មិនមានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូក្នុងដំណាក់កាលព្យួរ ឬ លុបចោល ឬ ដកហូតដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាឡើយ ។

៣-បន្ទាប់ពីបានអនុវត្តវិធានការកែតម្រូវរួចហើយ មន្ទីរពិសោធន៍មូលដ្ឋានដែលត្រូវបានព្យួរ ត្រូវធ្វើលិខិតជូនដំណឹងមកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីអនុវត្តនីតិវិធីត្រួតពិនិត្យនិងវាយតម្លៃ និងធ្វើតេស្តប្រៀបធៀបឡើងវិញ ។ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អាចលុបចោលការព្យួរបញ្ជិកា លិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ក្នុងករណីរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃ និង ការធ្វើតេស្តប្រៀបធៀបទទួលបានលទ្ធផលវិជ្ជមាន។ ⁄

**ប្រការ ១០ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១ :** អគ្គនាយកនៃក្រសួង អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ នាយកខុទ្ទកាល័យ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ១១
- ឯកសារ-កាលប្បវត្តិ